# បដិមានៃព្រះរាជាខ្មែរជ័យវរ្ម័នទី៧*

George Cœdès
*Membre de L'Institut*

ព្រះបាទជ័យវរ្ម័នទី៧ ជាព្រះរាជាតែមួយអង្គគត់នៃកម្ពុជាសម័យបុរាណ ដែលកាលពីមុនខ្ញុំបានរៀបរាប់ជីវប្រវត្តិត្រួសៗ[១]។ ចំណុចនេះងាយយល់ទេ ត្បិតមានតែស្តេចអង្គនេះប៉ុណ្ណោះដែលយើងមានរូបស្នងធ្វើអំពីថ្ម។

តើកាលពីមុនជំនាន់ព្រះអង្គ ពុំដែលមានព្រះរាជាណាមានបដិមាស្នងទេឬអ្វី? ត្រង់នេះត្រូវធ្វើការបញ្ជាក់បន្តិច។ តាំងពីដើមសម័យអង្គរពោលគឺពីស.វ.ទី៩មក គេប្រទះឃើញនូវបដិមារូបទេព ដែលមនុស្សម្នាគោរព ដោយសន្មតថាក្ខន្ធឬវិញ្ញាណបុគ្គលណាមួយស្ថិតនៅរលាយចូលគ្នានឹងវិញ្ញាណនៃទេពជាម្ចាស់រូបនោះ។ សិលាចារិកហៅបដិមាប្រភេទនេះថា "*យសសរីរ*" មានន័យថា "កាយដែលប្រកបទៅដោយយស" ហើយគេច្រើនហៅជាភាសាបារាំងថា "statues-portraits"[៣]។ ប៉ុន្តែបដិមាទាំងនោះ គេពុំបានឆ្លាក់ឡើង ក្នុងបំណងធ្វើរូបរាងមុខមាត់ឲ្យដូចបុគ្គលដែលខ្លួនស្នងនោះឡើយ។ បដិមានិមួយៗ ស្នងទេពណាមួយនៃសាសនាឥណ្ឌា ដែលគេសន្មតថាបុគ្គលនោះភ្ជាប់ក្ខន្ធទៅជាមួយ។ ទិដ្ឋភាពពីក្រៅនៃរូបនោះជារូបដែលគេនិយមទូទៅ តាមសម័យកាលរបស់ខ្លួន ពុំខុសអ្វីសោះឡើយពីរូបទេពសុទ្ធសាតធម្មតា។ ប្រការដែលធ្វើឲ្យគេដឹងអំពីបុគ្គលិកលក្ខណៈនៃបដិមាពិសេសណាមួយ គឺគេដឹងដោយឃើញមានចារនាមនៅលើមេទ្វារបន្ទប់ប្រាសាទដែលគេតម្កល់បដិមានោះ ឬមួយក៏ដោយសារសិលាចារិកដែលពិពណ៌នាអំពីការកសាងប្រាសាទនោះ។ ដូច្នេះទិដ្ឋភាពក្រៅពុំមែនជាបដិមាឆ្លាក់តាមមុខមាត់អភិជនឬស្តេចដែលមានពិតប្រាកដនោះទេ គឺជារូបទេពដែលទទួលនាមអភិជនឬស្តេចនោះមកបញ្ចូលដាក់ខ្លួន ដើម្បីឲ្យអ្នកទាំងនោះទទួលការបូជាព្រមគ្នានិងខ្លួនដែរ[៤]។

ប៉ុន្តែនៅភាគទី៤នៃស.វ.ទី១២ មានការផ្លាស់ប្តូរ។ ជំនាន់នោះ ដែលត្រូវនិងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ទំនៀមភ្ជាប់បុគ្គលទៅនឹងទេពដែលពោលមកនេះ គឺគេនិយមពេញទំហឹងនៅមជ្ឈដ្ឋានស្តេចនិងអភិជន មិនថាអនុវត្តទៅលើតែបុគ្គលដែលចែកស្ថានហើយប៉ុណ្ណោះទេ គឺប្រព្រឹត្តទៅចំពោះអ្នកដែលនៅរស់ទៀតផង។ ចំណុចនេះយើងដឹងច្បាស់តាមសិលាចារិកភិមានអាកាស ដែលនិពន្ធឡើងដោយព្រះអគ្គមហេសីឥន្ទ្រទេវី[៥]។ សិលាចារិកនោះឲ្យយើងដឹងថា ព្រះនាងជ័យរាជទេវីដែលត្រូវជាព្រះអនុជ ហើយធ្លាប់ជាព្រះរាជអគ្គមហេសីមុននោះ បាន "សាងតាមគ្រប់ទីកន្លែងនូវបដិមាព្រះបិតា, ព្រះមាតា, ព្រះអនុជ, មិត្រសម្លាញ់, សាច់សាលោហិត, សណ្តានជិតឆ្ងាយដែលព្រះនាងស្គាល់ ឬមួយគ្រាន់តែធ្លាប់ឮឈ្មោះ"។

---

* ប្រែសម្រួលដោយ អាំង ជូលាន ពីអត្ថបទដើមឈ្មោះ "Les statues du roi khmer Jayavarman VII", *Comptes Rendus de l'Academie des Inscriptions et Belles-Lettes*, juillet-octobre 1958, p. 218-226។

[១] *Un grand roi du Cambodge : Jayavarman VII*, Phnom Penh, 1935.

[២] *BEFEO*, XL, p. 325, 328.

[៣] កំណត់អ្នកប្រែ ៖ មានន័យថា បដិមាដែលឆ្លាក់តាមមុខមាត់ និងរូបរាងពិតប្រាកដនៃបុគ្គលណាម្នាក់។

[៤] G. Cœdès, "Note sur l'apothéose au Cambodge", *BCAI*, 1951, p. 38.

[៥] *Inscriptions du Cambodge*, II, p. 180.

ពាក្យនេះ ឃើញថាត្រូវនឹងចំនួនបដិមាដ៏ច្រើនលើសលុបដែលយើងបានប្រទះឃើញ ហើយដែលស្ទង់ឲ្យព្រះញាត្តិវង្ស។ បើស្ទង់ឲ្យប្រុស គេឆ្លាក់តាមលក្ខណៈព្រះលោកេស្វរ ត្បិតទេពនេះទទួលការគោរពបូជាពីព្រះរាជា ហើយជាទេពដែលគ្រប់គ្រងការពាររាជធានីផង។ បើស្ទង់ឲ្យស្រី គឺឆ្លាក់តាមរូបភាព "ប្រាជ្ញាបារមិតា"[៦] ដែលគេប្រៀបថាជាមាតានៃព្រះពុទ្ធអង្គ។ បដិមាទាំងនេះ ពុំខុសអ្វីពីប្រភេទដែលពោលពីមុនមកនោះទេ គឺគេឆ្លាក់ជារូបរាងដែលនិយមតាមគ្នា ដោយមិនចម្លងតាមភិនភាគមនុស្សណាម្នាក់ដែលមានពិតឡើយ។ ប្រការនេះធ្វើឲ្យយើងមានអារម្មណ៍ថា ហាក់ដូចជាគេឆ្លាក់ម្តងៗមានរាប់សិប តម្រៀបទុកនៅរោងជាងណាមួយ សម្រាប់យកទៅប្រើប្រាស់ឲ្យទាន់ពេលវេលា ពេលមានតម្រូវការ។ លុះដល់ពេលអភិសេកឲ្យក្លាយទៅជាបដិមាបូជា គេគ្រាន់តែថ្វាយនាមទៅរូបលោកេស្វរ ឬប្រាជ្ញាបារមីនោះ ដោយយកនាមនៃបុគ្គលស្រី ឬប្រុស ដែលមានពិតទៅបញ្ចូលជាមួយ។ រីបុគ្គលនោះក៏ភ្ជាប់អាត្ម័នទៅជាមួយទេពតាមវិធីនោះឯង។ ប៉ុន្តែនៅសម័យនោះ មានបដិមាមួយចំនួនដែលមិនដូចគេដទៃ ដោយសារជាងឆ្លាក់ហាក់ដូចជាចង់ចម្លងគ្រាប់តាមរូបមនុស្សផ្សេងៗដែលមានមែនពិត។ ឧទាហរណ៍មួយដែលគួរឲ្យកត់សម្គាល់ គឺរូបទេពប្រាជ្ញាបារមី ដែលយើងមើលឃើញជារូបក្មេងស្រីជំទង់ទើបតែដុះដោះ ថ្ពាល់ពេញមូល ហើយដែលលក្ខណៈខ្លះៗទៀតធ្វើឲ្យយើងជឿថា គេឆ្លាក់ឲ្យដូចកុមារីណាមួយដែលមានមែន[៧]។

នៅក្នុងអត្ថបទឈ្មោះ "L'art du règne de Jayavarman VII" លោក Jean Boisselier បានសិក្សាពន្យល់ក្បោះក្បាយអំពីទំនោរនៃចម្លាក់ខ្មែរនាចុងស.វ.ទី១២នេះ ដោយឲ្យឧទាហរណ៍យ៉ាងស្តែងមួយចំនួនទៀត ដើម្បីសង្កត់បញ្ជាក់អំពីការធ្វើឲ្យបដិមាមានបុគ្គលិកលក្ខណៈ[៨]។ ទំនោរថ្មីនេះហាក់ដូចជាមិនចេញកំណើតមកពីឥណ្ឌាទេ ព្រោះឥណ្ឌានិយមឆ្លាក់រូបស្តេចខ្លួននៅរាល់សម័យកាលក៏មែនពិត ប៉ុន្តែពុំដែលគិតថាចម្លាក់និមួយៗ ត្រូវធ្វើឲ្យដូចរូបស្តេចពិតប្រាកដឡើយ។ ថ្វីត្បិតតែព្រះរាជាឥណ្ឌាភ្ជាប់អាត្ម័នទៅនិងទេពក៏ដោយ រូបចម្លាក់ព្រះអង្គដែលគង់លើបល្ល័ង្ក ឬក៏ក្នុងឥរិយាបទប្រណម្យនោះ គេពុំដែលឆ្លាក់គ្រាប់តាមឲ្យដូចព្រះភក្ត្រនិងរាងកាយព្រះអង្គពិតឡើយ។ បើមើលតែពីក្រៅ បដិមាទាំងនោះជារូបទេពដែលគេនិយមសន្មតមកតៗគ្នាតាមក្បួនបដិមាសាស្ត្រទូទៅ[៩]។ ហេតុនេះ ទំនោរទៅរកធម្មជាតិ (ពោលគឺឆ្លាក់តាមមុខមាត់រូបរាងនៃបុគ្គលដែលមានមែន) ដែលលោក Boisselier ប្រៀបប្រដូចទៅប្រតិកម្មនៃ "អាម៉ានី" ចំពោះសិល្បះអេហ្ស៊ីបនោះ គឺជាការបង្កើតថ្មីមួយទៀតដែលផុះចេញឡើងពីមហារាជនេះ។

ក្នុងចំណោមចាយាលក្ខណ៍អំពីថ្មដែលស្ថាបនាឡើងជំនាន់នោះ មានមួយក្រុមហាក់ដូចជាបង្ហាញរូបព្រះរាជាផ្ទាល់ ព្រមទាំងព្រះរាជអគ្គមហេសីទីមួយ ដែលមាននៅក្នុងសិលាចារិកពោលមកពីលើ។ តាមពាក្យពេចន៍នោះ ព្រះនាងឥន្ទ្រទេវី "បានសាងព្រះរូបជាច្រើននៃព្រះនាងជ័យរាជទេវី (ជាព្រះអនុជ) ព្រមដោយព្រះរូបព្រះរាជាផង តម្កល់នៅគ្រប់បុរីនានា"[១០]។

មកទល់ពេលនេះ គេប្រទះឃើញរូបមនុស្សប្រុសចំនួនបួន ដែលពិសេសត្រង់ចំណុចថាពុំមែនជារូបទេព ឬក៏មនុស្សដែលភ្ជាប់អាត្ម័នជាមួយទេព[១១] ហើយដែលស្ទង់ឲ្យរូបមនុស្សតែម្នាក់។ មនុស្សនោះ ខ្ញុំជឿថាជាព្រះបាទជ័យវរ្ម័នទី៧។ រូបដែលបានប្រទះឃើញដំបូងបង្អស់ គេតម្កល់ទុកនៅសារមន្ទីរក្រុងបាងកក។ រូបនោះរកឃើញនៅភិម័យ ពោលគឺប្រាសាទខ្មែរជំនាន់ស.វ.ទី១២ ដែលសព្វថ្ងៃនៅទឹកដីសៀម[១២]។ កាលដើមឡើយ រូបនោះស្ថិតនៅក្នុងអាគារមួយដែលនៅខាងអាគ្នេយ៍នៃប៉មកណ្តាល[១៣]។ គឺជារូបមនុស្សប្រុសម្នាក់ ដែលមានទំហំធំជាងធម្មជាតិ, រាងក្រអាញ ហើយមាន

---

[៦] កំណត់អ្នកប្រែ ៖ ពោលឲ្យស្រួលស្តាប់តាមខ្មែរនិយាយសព្វថ្ងៃគឺ "ប្រាជ្ញាបារមី"។

[៧] J. Boisselier, *Tendances de l'art khmer*, p. 101, pl.XXI.

[៨] *Bulletin de la Société des études Indochinoises*, Saigon, N.S. XXVIII, 1952, p.265.

[៩] យ៉ាងហោចណាស់ នេះជាយោបល់នៃអ្នកឯកទេសធំៗដូចជាលោក A.K.Coomaraswamy (អារម្ភកថានៃសៀវភៅ *Portrait sculpture in South India* ដែលជាស្នាដៃនៃលោក T.G. Aravamuthan, X-XI) ព្រមទាំងអ្នកស្រី Stella Kramrisch (*Indian Sculpture*, p. 81.)។ ប៉ុន្តែរូបភាពច្រើននៅក្នុងសៀវភៅលោក Aravamuthan ហាក់ដូចជាបង្ហាញថាមានការឆ្លាក់តាមធម្មជាតិមនុស្សមែន គ្រាន់តែពុំច្បាស់ថា តើចម្លងតាមមុខមាត់បុគ្គលណាមួយដែលមានពិតមែនឬអត់។

[១០] លោក L. Finot យល់ច្រឡំថា "...ព្រមដោយរូបព្រះរាជានិងរូបព្រះនាងផ្ទាល់ផង..." (*BEFEO*, XXV, p. 392)។ ខ្ញុំពុំបានគិត ក៏យកការបកប្រែច្រឡំនោះមកផ្សព្វផ្សាយម្តងទៀតនៅក្នុង *Inscriptions du Cambodge*, II, p. 180។

[១១] កំណត់អ្នកប្រែ ៖ សូមមើលនៅខាងលើ ត្រង់ប្រការ "យសសិរី"។

[១២] G. Cœdès, *Musée de Bangkok (Arts Asiatica, XII)*, pl. XVIII-XIX.

[១៣] E. Aymonier, *Le Cambodge*, II, p. 120; L. de Lajonquière, *Inventaire*, II, p. 281; E. Seidenfaden, "An excursion to P'imai", *Journal of the Siam Society*, XVII, 1923, p.11.





ព្រះរូបនៃព្រះបាទជ័យវរ្ម័នទី៧

ព្រះកេសរកឃើញនៅព្រះខ័ន (កំពង់ស្វាយ)
កាលពីឆ្នាំ ១៩៥៨

ព្រះកេសរកឃើញនៅអង្គរធំ
កាលពីឆ្នាំ ១៩៣១

សាច់បន្តិច, អង្គុយពែនភ្នែននៅលើបល្ល័ង្កមូលមួយដែលពុំទាន់ខាត់សំអាតឲ្យរលីង, វែលងខ្លួនទទេហើយឈ្ងោកទៅមុខបន្តិច, ឯចង្កាក៏បញ្ចុចបន្តិចមករកទ្រូង។ រូបនោះនៅក្នុងឥរិយាបទប្រណម្យ ឬមួយក៏ឥរិយាបទនៃយោគីម្នាក់ដែលកំពុងស្មឹងស្មាធិ៍។ ដៃទាំងពីរបាត់ទៅហើយ ប៉ុន្តែដោយនៅលើជើងយើងពុំឃើញមានស្លាកស្នាមបាក់របេះអ្វីទាំងអស់ យើងដឹងថាដៃនោះពុំប៉ះនិងជើងទេ។ ដូច្នោះ ពុំមែនជាឥរិយាបទមនុស្សធ្វើសមាធិឡើយ។ ខ្ញុំយល់ថាមនុស្សនោះផ្គុំដៃទៅមុខទ្រូង ក្នុងកាយវិការប្រណម្យ ឬធ្វើតង្វាយទៅទេពណាមួយដែលនៅចំពីមុខ។ លក្ខណៈទូទៅនៃមុខ គឺមានភាព "ធូន" ៖ ប្រមុះនិងមាត់ក្រាស់បន្តិច, ថ្ពាល់ពេញមូល, ភ្នែកបិទ សមនិងឥរិយាបទទូទៅនៃមនុស្សកំពុងស្មឹងស្មាធិ៍ ឬអធិដ្ឋាន។ សក់ស្កួតសិតទៅក្រោយបួងចេញជាកំប៉ោយមូលទៅលើក្បាល ខិតទៅខាងក្រោយបន្តិច។ កំប៉ោយនោះពុំមែនជាកំប៉ោយនៅលើក្បាលពួកព្រាហ្មណ៍ដែលផ្គុំជាកញ្ចុំ ច្បូតឡើងលើហើយខាងចុងបត់ធ្លាក់មកក្រោយវិញ ដូចយើងធ្លាប់ឃើញតាមចម្លាក់នានាឡើយ។ ម្យ៉ាងទៀត ដោយរូបនោះពុំឃើញមានពាក់ខ្សែឈៀងធ្វើអំពីអំបោះស (ហៅថា "យជ្ញោបវិត") ពោលគឺលក្ខណៈសម្គាល់នៃព្រាហ្មណ៍ យើងដឹងថាពុំមែនជារូបព្រាហ្មណ៍ណាមួយទេ។ ថ្វីត្បិតតែលើរូបនោះគ្មានកេតណភណ្ឌអ្វីមួយសម្គាល់ថាជាស្តេចក៏ដោយ អ្នកស្រុកនៅតំបន់ប្រាសាទភិម័យ អះអាងថាជារូបព្រះបាទព្រហ្មទត្ត ដែលនៅក្នុងរឿងព្រេងជាស្តេចនគរពារាណសីដូចមាននៅក្នុងជាតកយ៉ាងសន្ធឹកសន្ធាប់។ មានប្រការពីរដែលគួរសម្គាល់។ មួយគឺនៅបាតជើងឆ្វេងមានរូបចក្រ ដែលជានិមិត្តរូបចក្រពត្រាធិរាជ។ មួយទៀត គឺនៅជិតនោះមានរូបស្រីម្នាក់អង្គុយលុតជង្គង់, ត្រគាកសង្កត់លើកែងជើង ប៉ុន្តែជាអកុសលបាត់ក្បាលព្រមទាំងដៃទៅហើយ។ អ្នកស្រុក

នៅទីនោះយល់ថាជានាងអរវិន្ទ ពោលគឺព្រះជាយានៃព្រះបាទព្រហ្មទត្ត។ ឥឡូវនេះ ចូរយើងមកពិនិត្យរូបមួយដែលគេរកឃើញនៅអង្គរ។ កាលពីឆ្នាំ១៩២៤ គេរកឃើញដងខ្លួននៅចន្លោះអង្គរធំ នឹងក្រោលរមាស។ ឯក្បាលគេប្រទះឃើញនៅឆ្នាំ១៩៣១ ក្នុងបរិវេណអង្គរធំ ចូលជុតពីទ្វារខ្មោចមកបន្តិច។ រូបនេះ គេរក្សាទុកនៅសារមន្ទីរភ្នំពេញ តាំងពីឆ្នាំ១៩៣៤មក[១៤]។

កាលដងខ្លួនទើបនឹងរកឃើញ លោក Henri Marchal ដែលជាអភិរក្សអង្គរ ចាប់អារម្មណ៍យ៉ាងខ្លាំង ថារូបនេះមានភាពប្លែកពីរូបធម្មតាដែលធ្លាប់ស្គាល់មក ហើយបានចុះក្នុងរបាយការណ៍លោកថាជា "រូបពោរពេញដោយអាថ៌កំបាំង ដែលរាងរៅទាំងមូល ធ្លាក់មានការប្រើតប្រៀងជាងទម្លាប់ដែលមានមកជាធម្មតា ថ្វីត្បិតតែនៅមានខ្វះនៅឡើយ"[១៥]។ ចំណែកឯខ្ញុំវិញ ខ្ញុំឃើញថារូបនោះដូចរូបនៅភិម័យខ្លាំងណាស់។ លោក Georges Groslier ដែលជាអភិរក្សសារមន្ទីរភ្នំពេញ ក៏ចាប់អារម្មណ៍ដូចខ្ញុំដែរ ព្រមទាំងបានសរសេរថា "កម្ពស់កំពស្មើរតែស្មើគ្នា, បល្ល័ង្កមូលធ្លាក់ពុំទាន់ហើយដូចគ្នា។ ប៉ុន្តែរូបដែលតាំងនៅសារមន្ទីរ Albert Sarraut[១៦] គ្មានចក្រនៅបាតជើង, គ្មានខ្សែក្រវាត់ចង្កេះប្រកបដោយក្បាច់លំអ, និងគ្មានកំពោយទៀតផង"[១៧]។ ជាការពិតហើយដែលពុំឃើញមានកំពោយ ប៉ុន្តែថ្មបែកនៅចំកន្លែងដែលអាចមានកំពោយនោះតែម្តង។ ក្រៅអំពីប្រការប៉ុន្មាននេះ មុខមាត់ព្រមទាំងរូបរាងនៃរូបទាំងពីរដូចគ្នាទាំងស្រុង។ ដោយសារខ្ញុំយល់ថា រូបទាំងពីរនេះស្នងឲ្យមនុស្សតែម្នាក់ នៅឆ្នាំ១៩៣៤ ខ្ញុំក៏បែកគំនិតប្រៀបធៀបរូបនេះ ទៅនិងរូបព្រះបាទជ័យវរ្ម័នទី៧ ដែលឃើញនៅលើផ្ទាំងចម្លាក់ប្រាសាទបាយ័ន្ត និងប្រាសាទបន្ទាយឆ្មារ ពោលគឺប្រាសាទពីរដែលសាងនៅក្នុងរាជ្យនោះ។ នៅកន្លែងជាច្រើនដែលគេនិទានអំពីព្រឹត្តិការណ៍ផ្សេងៗជំនាន់នោះ យើងតែងឃើញមានមនុស្សប្រុសម្នាក់ មានទំហំខ្លួនធំលើសគេ ហើយដែលមនុស្សនៅជុំវិញសម្តែងការលំទោនទៅរក ធ្វើឲ្យយើងគិតថាជាស្តេច ថ្វីត្បិតតែពុំឃើញមានកេតនភណ្ឌណាមួយជាទីសម្គាល់ក៏ដោយ។ ការបកស្រាយនេះ ត្រូវគ្នានិងចារិកអក្សរថ្មពីរកន្លែង ដែលប្រទះឃើញនៅប្រាសាទបាយ័ន្តក្រោមរូបពីរាយតគ្នា នៅថែវចម្លាក់ខាងលិចចំហៀងខាងជើង[១៨]។ តួអង្គនេះ ដកខ្លួនទៅក្នុងព្រៃដើម្បីទទួលរាជពិធីមួយហៅថា "ឥន្ទ្រាភិសេក" ក្រោយពីបានឈ្នះសង្គ្រាមមួយ។ លើសិលាចារិកទាំងពីរ តួអង្គនោះមានងារជាភាសាខ្មែរ ដែលជាងារព្រះមហាក្សត្រ។ រូបនៅលើផ្ទាំងចម្លាក់នេះ ពុំអាចជានរណាក្រៅពីព្រះបាទជ័យវរ្ម័នទី៧ឡើយ។ លុះយកទៅប្រៀបជាមួយបដិមាពីរដែលពោលមកខាងលើ ឃើញថាមានលក្ខណៈដូចគ្នា ៖ មានឱជំទ្រលុក, មុខទូទៅមានភាព "ធ្ងន់", មានកំពោយតូច។ សេចក្តីសន្និដ្ឋាន គឺតួអង្គនោះតែមួយទេ។ ម្យ៉ាងទៀត អ្នកស្រុកនៅតំបន់ភិម័យក៏និយាយថារូបដែលឃើញនៅប្រាសាទភិម័យជារូបស្តេចដែរ។ តាមពិតទៅ រូបទាំងប៉ុន្មាននោះពុំមែនបង្ហាញអំពីស្តេចទ្រង់គ្រឿង ពោលគឺដែលមានកេតនភណ្ឌគ្រប់យ៉ាងនោះឡើយ។ គឺជាស្តេចដែលបានជម្រុះអស់ នូវភាពសង្ហារស្ងប់ស្ងៀម ហើយមកដាក់ព្រះអង្គក្នុងភាពប្រណម្យ ឬស្មឹងស្មាធិ៍។ រូបនៅប្រាសាទភិម័យ ដើមឡើយស្ថិតនៅក្នុងប៉មមួយដែលបែទៅរកប៉មធំកណ្តាល។ ចំណុចនេះធ្វើឲ្យយើងយល់ថា រូបនោះមានឥរិយាបទជាមនុស្សប្រណម្យ ឬក៏ជាសាសនិកដែលស្មឹងស្មាធិ៍ ផ្តោតភ្ជាប់មនោទៅនឹងទេពដែលខ្លួនគោរពបូជា។

មកទល់ឆ្នាំនោះ[១៩] មានតែបដិមានៅភិម័យនិងនៅអង្គរពីរនេះទេ ដែលគេអាចជឿថាជាព្រះរូបនៃព្រះបាទជ័យវរ្ម័នទី៧។ តាមពិត មានព្រះកេសពីរទៀត ដែលមើលទៅឃើញថាជារូបស្នងនៃព្រះរាជានោះដែរ។

ព្រះកេសទីមួយ ដែលប្រហែលជារកឃើញនៅអង្គរ ត្រូវគេទុកនៅសារមន្ទីរនាវាចរក្រុងម៉ាកសី *(Musée Maritime de Marseille)* ហើយបានទទួលការផ្សព្វផ្សាយពីសំណាក់លោកគ្រូខ្ញុំ គឺលោក Alfred Foucher[២០]។ ជំនាន់នោះ យើងដឹងតិចតួចខ្លាំងណាស់អំពីព្រះបាទជ័យវរ្ម័នទី៧ ដូច្នេះលោកគ្រូខ្ញុំពុំអាចចាប់អារម្មណ៍ថា រូបនោះជារូបនរណាឡើយ។ គាត់ស្មានថា ប្រហែលជាព្រះកេសព្រះពុទ្ធរូប ដោយពោលបើកចំហរថា "អាចជារូបជនណាមួយដែលគេគោរពបូជា មិនមែនជាវីរបុរសទេ តែជាព្រះមហាថេរណាមួយ"។ ប៉ុន្តែឥឡូវនេះ ក្រោយពីបានស្គាល់រូបទាំងពីរ

---

[១៤] J. Boisselier, *Tendances de l'art khmèr*, p. 93, pl.XIX.

[១៥] *BEFEO*, XXIV, p. 647.

[១៦] កំណត់អ្នកប្រែ ៖ ឈ្មោះសារមន្ទីរជាតិភ្នំពេញកាលជំនាន់នោះ។

[១៧] *BEFEO*, XXXIV, p. 750.

[១៨] *BEFEO*, XXXII, p. 74.

[១៩] កំណត់អ្នកប្រែ ៖ ឆ្នាំ១៩៣៤។

[២០] *BCAI*, 1912, p. 218, Pl. XV.

នៃសារមន្ទីរបាងកកនិងភ្នំពេញហើយ យើងឃើញថាចំណុចសំខាន់សឹងដូចគ្នា ៖ ទម្រង់មុខទូទៅ, កំប៉ោយតូចលើព្រះកេស។ ដូច្នេះគ្មានអ្វីគួរឲ្យសង្ស័យទៀតទេ ព្រះកេសដែលគេលែងនឹកនាតាំងពីឆ្នាំ១៩១២មកនោះ គឺជារូបទីបីនៃព្រះបាទជ័យវរ្ម័នទី៧។

រូបទីបួន ដែលជាដើមអាទិ៍នាំឲ្យខ្ញុំធ្វើបាឋកថានេះ ត្រូវបានលោក Jean Filliozat ជាចាងហ្វាងសាលាបារាំងចុងបូព៌ា និងលោក Laur ជាអភិរក្សអង្គរ រកឃើញកាលពីថ្ងៃទី១២មករាឆ្នាំនេះ[២១] នៅប្រាសាទព្រះខ័ន។ មិនមែនព្រះខ័ននៅអង្គរទេ គឺព្រះខ័នដែលនៅចម្ងាយ១០៤គ.ម. ខាងកើតទៅទៀត ក្នុងខេត្តកំពង់ធំ [២២]។ ព្រះកេសនោះមានទំហំដូចគ្នានឹងព្រះកេសមុនៗដែរ (កំពស់ប្រមាណ០,៣៥ម, ទទឹងប្រមាណ០,២៧ម) ហើយទើបតែព្រះសង្ឃមួយអង្គប្រទះឃើញកប់នៅក្នុងគំនរដី នៅកៀនខាងកើតនៃប៉មកណ្ដាល។ លោក Filliozat ក៏យល់ភ្លាមថា រូបនោះនៅក្នុងពពួករូបដែលពោលមកខាងលើ ៖ ទម្រង់មុខដូចគ្នា, មានកូនកំប៉ោយដូចគ្នា។ ដងខ្លួនប្រហែលនៅទីណាមួយក្នុងប្រាសាទជាពុំខាន ហើយគួរតែយើងរុករកដើម្បីពិនិត្យថា តើខ្លួននោះសមនឹងមនុស្សដែលមានភាពជាមនុស្សក្នុងយុវវ័យ ឬយ៉ាងណា[២៣]។ ប្រសិនបើមើលទៅឃើញថា ជារូបព្រះបាទជ័យវរ្ម័នទី៧កាលនៅក្មេង គឺមានន័យថា គំនិតរបស់លោក Philippe Stern ដែលថា ប្រហែលជាព្រះបាទធរណីន្ទ្រវរ្ម័នទី២ជាអ្នកសាងប្រាសាទព្រះខ័ននោះពិតជាត្រឹមត្រូវមែន។ ព្រះបាទជ័យវរ្ម័នទី៧ជាបុត្រ ប្រហែលគង់នៅទីនោះ មុននឹងឡើងសោយរាជ្យនៅអង្គរ។ បើដូច្នោះមែន យើងអាចយល់បានថាកាលជំនាន់នោះ ព្រះអង្គនៅក្មេងនៅឡើយ បានជាបដិមាក៏បានបង្ហាញអំពីភាពយុវបុរសដូចគ្នា។ នេះគ្រាន់តែជាសមត្ថិកម្មនៅឡើយ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងមានព្រះរូបបួននៃព្រះបាទជ័យវរ្ម័នទី៧ ដែលយើងជឿច្បាស់ថាព្រះនាងឥន្ទ្រទេវីបានបញ្ជាឲ្យគេសាង។ ម្យ៉ាងទៀតខ្ញុំជឿថាយើងមានព្រះរូបព្រះនាងជ័យរាជទេវីចំនួនបួនដែរ ដែលសាងឡើងក្រោយពីព្រះនាងចូលទីវង្គតទៅ។ យើងបានឃើលហើយថា ក្នុងប្រាសាទភិម័យ នៅជិតបដិមាព្រះបាទជ័យវរ្ម័នទី៧ មានរូបមួយទៀតដែលអ្នកស្រុកយល់ថាជាមហេសីស្ដេច។ ឥរិយាបថលុតជង្គង់នោះ គឺដូចគ្នានឹងរូបស្រីបីទៀត។ ក្នុងនោះពីរឃើញនៅក្នុងបរិវេណប្រាសាទព្រះខ័ន (អង្គរ) ឯទីបីនៅខាងត្បូង ក្រៅបរិវេណប្រាសាទ ចន្លោះគ្នានឹងកំពែងអង្គរធំខាងជើង ហើយពុំឆ្ងាយប៉ុន្មានពីចំណុចដែលគេរកឃើញដងខ្លួននៃបដិមាព្រះបាទជ័យវរ្ម័នទី៧ កាលពីឆ្នាំ១៩២៤ឡើយ។

បដិមារូបស្រីដែលគេស្គាល់ជាងគេ គឺរូបប្រាជ្ញាបារមីដែលតាំងនៅសារមន្ទីរ Guimet[២៤]។ ភក្ត្រនោះល្អជាងគេ បើប្រៀបទៅរូបដទៃទៀតនៅជំនាន់នោះ ហើយបង្ហាញឲ្យឃើញថា ការឆ្លាក់នោះប្រិតប្រៀងបំផុត ជាហេតុឲ្យយើងជឿថា ជារូបឆ្លាក់ចម្លងដោយកែលំអខ្លះ តាមមនុស្សដែលមានពិតនៅក្នុងត្រកូលអភិជន ពោលឲ្យចំគឺអគ្គមហេសីតែម្ដង។ រូបទាំងប៉ុន្មានសុទ្ធតែបាត់ដៃទៅហើយ រីឯឥរិយាបថបង្ហាញថាជាការប្រណម្យអធិដ្ឋាន ឬក៏ថ្វាយតង្វាយអ្វីមួយ។ បានជាពោលដូច្នេះ មកពីយើងស្គាល់រូបឯទៀតមួយចំនួនដែលលុតជង្គង់ដូចគ្នា ហើយដែលកាន់ថាសតង្វាយនៅដៃមួយ ឬដៃនោះផ្គុំអញ្ជលីទៅមុខដើមទ្រូង។ រីឯរូបទាំងបួនដែលបានពោលមក ក៏ប្រហែលពុំខុសអ្វីអំពីនោះឡើយ។

ដូច្នេះឃើញថា យើងបានប្រទះបដិមាប្រុសបួន ស្រីបួន ដែលក្នុងនោះមួយគូឃើញនៅកន្លែងដើម ក្នុងប៉មមួយនៃប្រាសាទភិម័យ ឯមួយគូទៀតនៅអង្គរ ក្រៅបរិវេណខាងត្បូងនៃប្រាសាទព្រះខ័ន។ ទាំងនេះសុទ្ធសឹងជាព្រះរូបនៃព្រះបាទជ័យវរ្ម័នទី៧ ព្រមទាំងព្រះនាងជ័យរាជទេវី ដែលបងស្រីរបស់ព្រះនាងបានឲ្យគេសាងតម្កល់នៅ "គ្រប់ក្រុងនានា"។ បដិមាទាំងនេះពុំមែនជារូបមនុស្សដែលភ្ជាប់អាត្ម័នទៅនឹងទេពទេ តែគឺជារូប "ទាយក" ឬរូបអ្នកមានសាទ្ធាដែលកំពុងប្រណម្យ។

បើពោលទាំងប៉ុន្មានមកនេះត្រូវនឹងការពិតមែន នៅមានបញ្ហាមួយទៀតថា ហេតុដូចម្ដេចបានជាគេឆ្លាក់រូបព្រះរាជាក្នុងសភាពជាមនុស្ស រីឯព្រះអគ្គមហេសីវិញតាមសភាពជាទេព គឺប្រាជ្ញាបារមី ដែលមានរូបព្រះពុទ្ធតូចឆ្មារមួយ ធ្វើសមាធិនៅពីមុខក្នុងសក់?

យើងដឹងថាព្រះអគ្គមហេសីចូលទីវង្គតរួចទៅហើយ ពេលដែលគេសាងរូបទាំងនោះ ដូច្នេះឆ្លាក់នៅក្រោមទិដ្ឋភាពនៃប្រាជ្ញាបារមី គឺស្របតាមទំនៀមនៅសម័យនោះមែនហើយ។ ចំណែកឯឥរិយាបថលុតជង្គង់ ក៏ពុំទាស់អ្វីនឹងឋានៈជាអគ្គមហេសីដែរ ទុកជាព្រះអង្គភ្ជាប់អាត្ម័នទៅនឹងទេពព្រមទាំងប្រណម្យបែរទៅរកប៉មដែលតម្កល់ទេពនោះក៏ដោយ។ រីឯព្រះរាជាវិញ គេអាចឆ្លាក់រូបស្នងក្នុងទិដ្ឋភាពបីយ៉ាង បើតាមគិតមើលទៅ។ ទីមួយតាមសភាពមនុស្សធម្មតា ទីពីរជាព្រះពោធិសត្វលោកេស្វរ និងទីបីជាព្រះពុទ្ធអង្គ។ បើយកលទ្ធភាពទីពីរមកពិនិត្យ ឃើញថាអាចច្រឡំនឹងបដិមា

---

[២១] កំណត់អ្នកប្រែ ៖ ឆ្នាំ១៩៥៩។

[២២] កំណត់អ្នកប្រែ ៖ សព្វថ្ងៃនៅក្នុងខេត្តព្រះវិហារ។

[២៣] កំណត់អ្នកប្រែ ៖ ដងខ្លួននោះគេទើបនឹងរកឃើញប្រមាណពីរឆ្នាំមុននេះ នៅក្នុងប្រាសាទ ដូចការប៉ង់របស់លោក George Cœdès មែន។

[២៤] *BEFEO*, XLIV, p. 652, 683.

ស្នងឲ្យសមាជិកព្រះញាត្តិវង្ស ឬអភិជននានា ដូចខ្ញុំបានពោលពីលើកមកហើយថា ជំនាន់នោះសម្បូណ៌ណាស់។ បើច្លាក់ក្រោមទិដ្ឋភាពជាព្រះពុទ្ធអង្គ គឺពុំទាស់អ្វី ព្រោះច្បាស់ជាព្រះរាជាភ្ជាប់ព្រះអង្គទៅនឹងព្រះពុទ្ធ ដូចពីជំនាន់មុនមកព្រះរាជានានាភ្ជាប់ព្រះអង្គទៅទេពហិណ្ឌូផ្សេងៗដែរ។ ត្រង់ប្រការនេះ គួរចាប់អារម្មណ៍លើសិលាចារិកប្រាសាទព្រះខ័នដែលនិយាយថា ព្រះរាជាបានសាងរូបព្រះជ័យពុទ្ធ[២៥] តម្កល់នៅបុរីចំនួន២៣ នៃព្រះរាជាណាចក្រ។ ជ័យពុទ្ធ គឺជានាមដែលភ្ជាប់បដិមា (ពុទ្ធ) មកតួអង្គព្រះរាជា (ជ័យ = ជ័យវរ្ម័ន) មិនខុសអ្វីពីទម្លាប់ដែលមានតរៀងមកយូរហើយនោះទេ។ នាមនេះ ប្រាកដជាសំដៅទៅលើបដិមាដែលគេគោរពបូជា ដោយបញ្ចូលបុគ្គលិកលក្ខណៈ ឬអាត្ម័នស្តេចនៅក្នុងនោះដែរ ហើយប្រហែលជាគេច្លាក់ចម្លងតាមព្រះភក្ត្រនិងព្រះកាយស្តេចពិតប្រាកដផង។ ត្រង់នេះគួរយើងពិនិត្យមើលព្រះកេសព្រះពុទ្ធមួយ ដែលតាំងនៅសារមន្ទីរ Guimet ហើយដែលមានប្រភពមកពីអង្គរ[២៦]។ ព្រះភក្ត្រនោះឥតមានដូចព្រះភក្ត្រព្រះពុទ្ធរូបទូទៅពីជំនាន់ជាមួយគ្នាទាល់តែសោះ[២៧]។ ក្នុងសៀវភៅកាតាឡុកអំពីសម្បុច្ច័យនៃសារមន្ទីរនោះ លោក Pierre Dupont លើកសំនួរឡើងថា ប្រហែលជាការច្លាក់ទម្រង់មុខនោះទទួលឥទ្ធិពលពី "ភិនភាគនៃជាតិសាសន៍"[២៨] អ្នកច្លាក់នោះឬអ្វី? ចំពោះខ្ញុំវិញ ខ្ញុំយល់យល់យ៉ាងខ្លីថា ជាភិនភាគ "ចម្លងតាមគម្រូ" បុគ្គលណាម្នាក់។ រីឯបុគ្គលដែលយើងឃើញថា មុខមាត់ទូទៅមានភាព "ធូន់", ថ្ពាល់ពេញមូលនោះ គឺពុំមែននរណាក្រៅពីព្រះបាទជ័យវរ្ម័នទី៧ឡើយ។ គេច្លាក់ព្រះរាជានេះក្នុងសភាពជាព្រះពុទ្ធ និយាយឲ្យចំទៅគឺព្រះជ័យពុទ្ធ[២៩]។ យើងបានឃើញថា គេច្លាក់បដិមានៃព្រះបាទជ័យវរ្ម័នទី៧ព្រមទាំងព្រះជាយា ដើម្បីតម្កល់ឲ្យប្រណម្យបែរទៅរកប៉មកណ្តាលនៃប្រាសាទ ហើយម្យ៉ាងទៀតបដិមាស្រីលុតជង្គង់ទាំងបួនដែលនិយាយពីលើមក ក៏ដូចគ្នាដែរ។ គេអាចច្លាក់ព្រះរាជាតាមសភាពជាព្រះពុទ្ធអង្គ ប៉ុន្តែពុំអាចឲ្យរូបនោះនៅក្នុងឥរិយាបថប្រណម្យ ឬធ្វើតង្វាយឡើយ ត្បិតព្រះពុទ្ធអង្គជាកំពូលលើលោក។ បើក្នុងសភាពមនុស្សធម្មតា បដិមាអាចបង្ហាញព្រះរាជាដែលទ្រង់គ្រឿងពេញលេញ ដូចមានឧទាហរណ៍បដិមាស្តេចភូមាព្រះនាម Kyanzittha ដែលតម្កល់នៅច្រកចូលវត្ត "អនន្ទ" នៅក្រុង Pagan។ រូបនោះលុតជង្គង់ ដៃប្រណម្យអញ្ជលី។ រីឯបដិមាព្រះបាទជ័យវរ្ម័នទី៧វិញ ឥតមានគ្រឿងអលង្ការ ឬព្រះសង្ហារអ្វីទាំងអស់។ ប្រការនេះក៏ប្រហែលមកពីព្រះអង្គភ្ជាប់អាត្ម័នទៅនឹងព្រះពុទ្ធអង្គរួចហើយ។ បើពិនិត្យរូបស្នងស្ថាបនិកប្រាសាទអង្គរវត្ត ពោលគឺព្រះបាទសូរ្យវរ្ម័នទី២ ដែលឃើញមានពីរកន្លែងលើផ្ទាំងចម្លាក់នៃប្រាសាទនោះវិញ ឃើញថាទ្រង់មកុដនិងអលង្ការគ្រប់យ៉ាង មិនដូចព្រះបាទជ័យវរ្ម័នទី៧ ដែលយើងមើលឃើញរូបនៅលើផ្ទាំងជញ្ជាំងប្រាសាទបាយន្តផង ប្រាសាទបន្ទាយឆ្មារផង ហើយដែលពុំឃើញមានគ្រឿងពិសេសណាមួយបញ្ជាក់ពីឋានៈជាព្រះមហាក្សត្រទាល់តែសោះ។

ក្នុងលទ្ធភាពបីដែលពោលនៅខាងលើនេះ ឃើញនៅសល់តែការបង្ហាញព្រះរាជាតាមសភាពជាមនុស្សប៉ុណ្ណោះ ប៉ុន្តែជាមនុស្សដែលបានច្លងផុតពីចំណងជំពាក់វាក់វិនទាំងឡាយនៃជីវិត ពោលគឺសាសនិកដែលលុះដោយធម៌សុទ្ធសាត។ លុះពិនិត្យទៅលើមរណនាមនៃព្រះបាទជ័យវរ្ម័នទី៧ –មហាបរមសៅគត– នោះ ឃើញថាអ្វីៗទាំងអស់សឹងស្របគ្នា។ ប្រការនេះត្រូវនឹងពាក្យលោក Alfred Foucher ស្តីអំពីព្រះកេសនៅសារមន្ទីរក្រុងម៉ាកសី ដែលថា "អាចជារូបជនណាមួយដែលគេគោរពបូជា មិនមែនជាវីរបុរសទេ តែជាព្រះមហាថេរណាមួយ"៕

---

[២៥] ល្បះ CXIV-CXXI, *BEFEO*, XLI, p. 295-296។

[២៦] លេខបញ្ជីសារពើភណ្ឌ 17482 (*BCAI*, 1931-1934, p. 116, nos 4-18)។ រូបនេះ គេតែងផ្សព្វផ្សាយជារឿយៗ ជាអាទិ៍ដោយ R.Grousset, *Histoire de l'Extrême-Orient*, II, pl. 32 ព្រមទាំង *Civilisations de l'Orient*, II, fig. 140 et 141។

[២៧] កំណត់អ្នកប្រែ ៖ ពោលគឺព្រះពុទ្ធរូបដែលច្លាក់តាមគ្នាជាទម្លាប់រៀងមក ដោយមិនវីរវល់ស្រង់យកភិនភាគមនុស្សណាមួយជាគម្រូឡើយ។

[២៨] កំណត់អ្នកប្រែ ៖ ពោលគឺច្លាក់តាមមុខមាត់ខ្មែរទូទៅ។

[២៩] មានព្រះពុទ្ធរូបមួយទៀតដែលគេប្រទះឃើញកាលពីឆ្នាំ១៩៤០ នៅយ៉ចូលពីខាងលិចទៅប៉មកណ្តាលនៃប្រាសាទព្រះខ័ន (អង្គរ)។ ពុទ្ធបដិមានេះ មានទម្រង់ភិនភាគស្រដៀងគ្នានឹងបដិមាដែលពោលនៅលើដែរ។ អាចថាជាបដិមានៃព្រះជ័យពុទ្ធមួយទៀតក៏សឹងបាន (*BEFEO*, XL, p. 489, pl. LIIA)។